ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍

# កិច្ចប្រជុំបូកសរុបលទ្ធផលប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេស

# ថ្នាក់ជាតិ បុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រយុទ្ធនឹងជំងឺអេដស៍

# ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦

# នៅសណ្ឋាគារ កាំបូឌីយ៉ាណា

## ១-សេចក្តីផ្តើម

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពិសេសលេខាធិការដ្ឋានក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ សហការ និងគាំទ្រថវិកាដោយ អង្គការសេវាសង្គមសុខភាពបុរស (MHSS) បានរៀបចំនូវកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅសណ្ឋាគារកាំបូឌីយ៉ាណា នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ ដោយមានការចូលរួមពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ក្រុមគោលដៅ ដែលជាបុរសស្រឡាញ់បុរស និងស្រីស្រស់ មកពីសហគមន៍ផ្ទាល់ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត រួមមាន ខេត្តពោធិ៍សាត់ បាត់ដំបង និងបន្ទាយមានជ័យ និងសៀមរាប ប្រមាណជាសែសិបនាក់។

## ២-គោលបំណង

១. ពិនិត្យមើលផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០១៦។

២. ពិនិត្យមើលបច្ចុប្បន្នភាព បទពិសោធន៍នៃការផ្តល់សេវាពិនិត្យសុខភាព និងឧបសគ្គនានាលើបទអន្តរាគមន៍ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅក្នុងប្រទេសកម្ពុជារបស់អង្គការជាដៃគូ។

តាមរយៈនៃកិច្ចប្រជុំ សមាជិកក្រុមការងារទាំងអស់រំពឹងថា នឹងទទួលបាននូវអនុសាសន៍ល្អៗពីកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីរៀបចំផែនការសកម្មភាពសំរាប់អនុវត្តឆ្នាំ២០១៦។

## ៣-កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន

កាលបរិច្ឆេទ : ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦

ទីកន្លែង : នៅសណ្ឋាគារ កាំបូឌីយ៉ាណា

វត្តមាន : អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិក្រុមគោលដៅ និងលេខាធិការដ្ឋានខេត្តពោធិ៍សាត់ បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ។

## ៤-វិធីសាស្ត្រ

កិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានប្រើប្រាស់វិធីសាស្ត្រសំខាន់ៗមួយចំនួនដូចជា ការបង្ហាញស្លាយ ការពិភាក្សាក្រុមធំ បទបង្ហាញវេទិកាសំណួរ និងចំឡើយរវាងអ្នកចូលរួម និងវាគ្មិន ព្រមទាំងការផ្តល់ជាអនុសាសន៍ ក្នុងការរៀបចំផែនការសកម្មភាព ដើម្បីលើកទិសដៅសំរាប់អនុវត្តការងារបន្ត។

## ៥-លទ្ធផល

កាលពីថ្ងៃអង្គារ៍ ទី២៩ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង៨:៣០នាទីព្រឹក នៅសណ្ឋាគារ កាំបូឌីយ៉ាណា ក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយអង្គការសេវាសង្គមសុខភាពបុរស(MHSS) បានរៀបចំនូវកិច្ចប្រជុំប្រចាំត្រីមាសរបស់ខ្លួនក្រោមកិច្ចដឹកនាំប្រជុំដោយឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយបានការឧបត្ថម្ភថវិកាពីអង្គការសេវាសង្គមសុខភាពបុរស និងសំរេចលទ្ធផលដូចខាងក្រោមៈ

១. មតិស្វាគមន៍ និងបើកកិច្ចប្រជុំ

មតិស្វាគមន៍ និងបើកកិច្ចប្រជុំ ដោយឯកឧត្តមអគ្គលេខាធិការ បានថ្លែងអំណរគុណដល់សមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានចូលរួមប្រជុំនាពេលនេះ និងបានអរគុណដល់អង្គការសេវាសង្គមសុខភាពបុរស ដែលបន្តឧបត្ថម្ភថវិកាដល់ការរៀបចំប្រជុំប្រចាំត្រីមាសនេះឡើង។ ឯកឧត្តមអគ្គលេខាធិការបានមានប្រសាសន៍ថា កិច្ចប្រជុំនេះ គឺដើម្បីពិនិត្យមើលផែនការសកម្មភាពរបស់ក្រុមការងារបច្ចកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០១៦ និងពិនិត្យមើលបច្ចុប្បន្នភាព បទពិសោធន៍នៃការផ្តល់សេវាពិនិត្យសុខភាព និងឧបសគ្គនានាលើបទអន្តរាគមន៍បង្ការក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅក្នុងប្រទេសកម្ពុជារបស់អង្គការជាដៃគូ។ ជាមួយគ្នានេះ ឯកឧត្តមប្រធានបាន

មានប្រសាសន៍បន្តទៀតថា ក្នុងបទអន្តរាគមន៍បង្ការលើក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ យើងត្រូវរិះរកវិធីសាស្ត្រថ្មីៗ ពិសេសផ្តោតលើខេត្តសំខាន់ៗ និងក្រុមលាក់មុខ ដើម្បីសម្រេចបាននូវគោលការណ៍៩០ ៩០ ៩០ នាឆ្នាំ២០២០ ។

២.ជាកិច្ចបន្តការធ្វើបទបង្ហាញ:

២.១ ការបង្ហាញពីផែនការសកម្មភាពនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០១៦។

យុទ្ធសាស្ត្រទី១ :បង្ការការឆ្លងមេរោគអេដស៍ថ្មីក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់

គោលដៅទី១:បង្កើនការប្រើប្រាស់សេវាធ្វើតេស្តឈាមដោយគ្មានការរើសអើង និងម៉ាក់ងាយដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់

| | |
|---|---|
| ១ | សម្របសម្រួលកិច្ចប្រជុំបង្កើនការប្រើប្រាស់សេវាមេរោគអេដស៍ជាមួយNCHADSអង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធ |
| ២ | ចុះអភិបាលកិច្ចទៅលើគុណភាពនៃការផ្តល់សេវាសុខភាព |
| ៣ | រៀបចំកិច្ចប្រជុំផ្តល់យោបល់ និងវាយតម្លៃបន្ទាប់ពីចុះអភិបាលកិច្ចមកពិភាក្សាជាមួយក្រុមការងារលេខាធិការដ្ឋាន |
| ៤ | រៀបចំកិច្ចប្រជុំសម្របសម្រួលថ្នាក់ក្រោមជាតិ (ថ្នាក់មូលដ្ឋាន) ដល់អ្នកផ្តល់សេវា គ្រួសារ និងអាជ្ញាធរដែនដី (ការរើសអើង និងការទទួលសេវាសុខភាព) |

យុទ្ធសាស្ត្រទី២: បង្កើត និងធានានិរន្តភាពបរិយាកាសគាំទ្រកម្មវិធីបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងកាមរោគសម្រាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់

គោលដៅទី២: បង្កើតការសហការ និងសម្របសម្រួលគ្រប់ដៃគូទាំងអស់

| | |
|---|---|
| ១ | រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការចូលរួមដល់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធក្នុងកម្មវិធីបង្ការមេរោគអេដស៍ ជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ តាមរយៈក្រសួងព័ត៌មាន |
| ២ | រៀបចំវគ្គពង្រឹងសមត្ថភាពដល់បណ្តាញបុរសស្រឡាញ់បុរស និងស្រីស្រស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ៣ | សម្របសម្រួលជាមួយ NCHADS, MoH និងដៃគូពាក់ព័ន្ធក្នុងការពង្រីកសេវាបង្ការ ថែទាំ និងគាំទ្រដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ |
| ៤ | រៀបចំកិច្ចប្រជុំសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីការកាត់បន្ថយការរើសអើង និងមាក់ងាយ ដើម្បីពង្រឹងការអនុវត្តន៍បទអន្តរាគមន៍បង្ការមេរោគអេដស៍ ជំងឺ<br>អេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ |

| | |
|---|---|
| ៥ | បង្កើតវេទិកាជាមួយសារព័ត៌មាន ដើម្បីកាត់បន្ថយការរើសអើងក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ |
| ៦ | រៀបចំវគ្គបណ្តុះបណ្តាលពិគ្រោះយោបល់ស្តីពីយេនឌ័រដល់ក្រុមការងារលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ |

យុទ្ធសាស្ត្រទី៣: ពង្រឹងសមត្ថភាពដៃគូពាក់ព័ន្ធ

គោលដៅទី៣: ពង្រឹងការចូលរួមរបស់អង្គការសហគមន៍ ដែលធ្វើការងារជាមួយក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅក្នុងការឆ្លើយតបនឹងមេរោគអេដស៍ ជំងឺអេដស៍

| | |
|---|---|
| ១ | រៀបចំប្រមូលរបាយការណ៍ជាមួយអង្គការដែលធ្វើការងារជាមួយក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ |
| ២ | បង្កើនសមត្ថភាពដល់ក្រុមការងារលេខាធិការដ្ឋាន ( Right) |
| ៣ | រៀបចំផ្លាស់ប្តូរបទពិសោធន៍តាមរយៈកម្មសិក្សា ឬការចូលរួមកិច្ចប្រជុំនានាជាមួយអ្នកពាក់ព័ន្ធ |

យុទ្ធសាស្ត្រទី៤: លើកកំពស់លើការប្រមូល និងប្រើប្រាស់ព័ត៌មានជាយុទ្ធសាស្ត្រ

គោលដៅទី៤: ត្រួតពិនិត្យ និងតាមដានកម្មវិធីក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ ត្រូវបានកែលំអរ និងវាយតម្លៃសមត្ថភាព ប្រសិទ្ធភាព និងផលប៉ះពាល់ នៃការធ្វើបទអន្តរាគមន៍

| | |
|---|---|
| ១ | ចុះត្រួតពិនិត្យ និងប្រមូលទិន្នន័យ ព័ត៌មាន ពីអង្គការក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ អ្នកផ្តល់សេវា និងសហគមន៍ក្រុមបុរសស្រឡាញ់បុរស និងក្រុមស្រីស្រស់ |
| ២ | បង្កើតទម្រង់ប្រមូលទិន្នន័យសម្រាប់ត្រីមាសនីមួយៗ |
| ៣ | ជំរុញឱ្យស្ថាប័នធ្វើការងារជាមួយបុរសស្រឡាញ់បុរស និងស្រីស្រស់ពង្រឹងការអនុវត្តន៍ការងារថ្នាក់សហគមន៍(សមត្ថភាព ប្រាក់ឧបត្ថម្ភ គ្រឿងលើកទឹកចិត្ត) |
| ៤ | រៀបចំកិច្ចប្រជុំ ឬវេទិការផ្លាស់ប្តូរយោបល់ជាមួយអង្គការពាក់ព័ន្ធ គ្លីនិក និងមណ្ឌលសុខភាព ដើម្បីផ្លាស់ប្តូរយោបល់ និងព័ត៌មាន |
| ៥ | រៀបចំកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរសនិងស្រីស្រស់ ប្រយុទ្ធនឹងជំងឺអេដស៍ |
| ៦ | រៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ របស់ក្រុមការងារលេខាធិការដ្ឋាន ប្រចាំឆ្នាំ ២០១៦ |
| ៧ | រៀបចំកិច្ចប្រជុំប្រចាំខែនៃក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រយុទ្ធនឹងជំងឺអេដស៍ |

២.២ ការបង្ហាញពីឧបសគ្គនានា

២.២.១ ចំនួនប៉ាន់ប្រមាណសរុបទូទាំងប្រទេសកម្ពុជា ៣០៨៩១នាក់

២.២.២ ចំនួនក្រុមគោលដៅដែលទទួលបានការអប់រំ

| ល.រ | រាជធានី ខេត្ត | បុរសស្រឡាញ់បុរស | ស្រីស្រស់ | សរុប | អង្គការដែលធ្វើការជាមួយMSM&TG |
|---|---|---|---|---|---|
| ១ | ភ្នំពេញ | ៣៤១១ | ៧៦៩ | ៤១៨០ | MHSS, MHC, SIT KHEMERA |
| ២ | សៀមរាប | ៨៥៥ | ៣១១ | ១១៦៦ | MHC |
| ៣ | បាត់ដំបង | ២៧៥៤ | ៣០៣ | ៣០៦៥ | MHSS |
| ៤ | បន្ទាយមានជ័យ | ១៧៨០ | ១៨៤ | ១៩៦៤ | MHSS |
| ៥ | ពោធិសាត់ | ៥៦៨ | ៥៩ | ៦២៧ | MHSS |
| ៦ | កំពង់ឆ្នាំង | ៥៤៨ | ៥៧ | ៦០៥ | MHSS |
| ៧ | កំពង់ស្ពឺ | ៤៩៦ | ៥១ | ៥៤៧ | MHSS |
| ៨ | ព្រះសីហនុ | ២៥០ | ៥០ | ៣០០ | KHEMERA |
| ៩ | កោះកុង | ៣០០ | ៣៣ | ៣៣៣ | MHC |
| ១០ | កំពង់ចាម | ៤៦១ | ៥២ | ៥១៣ | MHC |
| ១១ | កណ្ដាល | ៨៧៩ | ២៧៨ | ១១៧៥ | MHC& SIT |
| ១២ | ព្រៃវែង | ៤៩៧ | ៤៩ | ៥៤៦ | MHSS |
| ១៣ | កំពង់ធំ | ៥១៨ | ៥៤ | ៥៧២ | MHSS |
| ១៤ | ប៉ៃលិន | ២៩២ | ៣០ | ៣២២ | MHSS |
|  | សរុប | ១៣៦២៧ | ២២៨០ | ១៥៩០៧ |  |

**២.២.៣** អង្គការជាដៃគូដែលអនុវត្តបទអន្តរាគមន៍បង្ការ និងទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ នៅកម្ពុជា:

- មានអង្គការចំនួន០៤ ដែលកំពុងអនុវត្តបទបង្ការនិងទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ ( MHSS, MHC, KHEMERA, SIT )។

- មានម្ចាស់មូលនិធិដែលកំពុងគាំទ្របទបង្ការ និងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ នៅកម្ពុជាដល់ចុងឆ្នាំ២១៧ KHANA-USAID-Flagship, Global Fund New Funding model & AHF។

២.២.៤ ស្ថានភាពប្រឈមរបស់ក្រុម MSM & TG ទៅទទួលសេវាសុខភាព:

• ៩០% នៃក្រុមបុរសស្រឡាញ់បុរសមិនបានធ្វើតេស្តឈាម ដោយសារគាត់គិតថាការប្រព្រឹត្តរបស់គាត់មិនមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ទេ។

• ១៥% នៃក្រុមបុរសស្រឡាញ់បុរស និង២១% នៃក្រុមស្រីស្រស់ពួកគាត់ជាប់រវល់ការងារ កំឡុងពេលអ្នកអប់រំតាមមូលដ្ឋានចុះធ្វើការអប់រំ និងធ្វើតេស្តឈាមនៅក្នុងសហគមន៍។

- ប្រហែល ១០% និយាយថាជឿជាក់លើដៃគូ ( ស្មោះត្រង់)
- ៧.៦% និយាយថា មិនបានធ្វើតេស្តឈាមដោយគាត់ខ្លាចថាគាត់បានឆ្លងមេរោគ

អេដស៍ ។

- ប្រហែល៧.៦% និយាយថាខ្លាចការម៉ាក់ងាយ និងការរើសអើង។
- ៦.៥% និយាយថាមិនស្គាល់មណ្ឌលធ្វើតេស្តឈាម។
- អង្គការដៃគូមិនបានគោរពតាមគោលការណ៍ណែនាំរបស់ថ្នាក់ជាតិ
- អ្នកអប់រំតាមមូលដ្ឋានមិនអាចធ្វើតេស្តជាពិសេសOWក្រោមគំរោងមូលនិធិសកល
- គោលនយោបាយស្វែងរកបរិយាកាស គាំទ្រ មិនបានអនុវត្ត

២.២.៥ ឧបសគ្គក្នុងការអុវត្តន៍បទអន្តរាគមន៍បង្ការមេរោគអេដស៍ ជំងឺអេដស៍:

- អត្រាធ្វើតេស្តឈាមនៅមានកំរិតទាប ( ៩០% បដិសេធន៍មិនធ្វើតេស្ត )
- មានការផ្លាស់ប្តូរ OW មានកំរិតខ្ពស់ ( ប្រហែល ៧០% ក្នុងមួយឆ្នាំ ៗ )
- ខ្វះខាត និងការផ្គត់ផ្គង់ប្រតិករសំរាប់ធ្វើតេស្តមិនទាន់ពេល
- ខ្វះខាតឧបករណ៍សំរាប់អនុវត្តការធ្វើតេស្តឈាម
- ពុំមានទូរទឹកកកសំរាប់រក្សាទុកទ្លដាក់ប្រតិករអោយគុណភាព
- គុណភាណ និងកំរិតនៃការផ្តល់ប្រឹក្សា របស់OW នៅមានកំរិតទាប
- ការស្វែងរកករណីចម្លងថ្មីនៅមានកំរិតទាបជាពិសេសក្រុមលាក់មុខ
- ខ្វះខាតប្រតិករសំរាប់ធ្វើតេស្តឈាម ជាពិសេសតេស្តស្វាយ

- ខ្វះឧបករណ៍សំរាប់អនុវត្តបំរើអោយការធ្វើតេស្តឈាម

២.៣ បទបង្ហាញពីបទពិសោធន៍ការផ្តល់សេវាសុភាពរបស់អង្គការវេជ្ជសាស្ត្រក្នុងក្តីសង្ឃឹមកម្ពុជា(MEC):

- MEC ផ្តល់នូវសេវាសុខភាពដែលមានគុណភាព សិទ្ធិជាមូលដ្ឋាន សេវាកម្មសុខភាពនិងយែនឌ័រ ដោយផ្តោតលើសុខភាព ផ្លូវភេទ និងសុខភាពបន្តពូជទៅដល់អ្នកដែលងាយរងគ្រោះក្នុងប្រទេសកម្ពុជា ។

- ជនគោលដៅ ស្ត្រីធ្វើការនៅសេវាកំសាន្ត បុរសរួមភេទជាមួយបុរស ក្រុមដែលងាយប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ និងអ្នកផ្ទុកមេរោគអេដស៍ ជំងឺអេដស៍។

- គោលបំណង កាត់បន្ថយអត្រាការរីករាលដាលនៃជំងឺកាមរោគ និងជំងឺអេដស៍ តាមរយៈការរួមភេទ ក្នុងចំណោមជនងាយរងគ្រោះថ្នាក់ដូចជា ស្ត្រីធ្វើការនៅតាមសេវាកំសាន្ត បុរសរួមភេទជាមួយបុរស និងការប្រើប្រាស់គ្រឿងញៀន។

- ការផ្តល់សេវា: ការផ្តល់សេវាថៃទាំ ព្យាបាលជំងឺកាមរោគ ការផ្តល់ប្រឹក្សា ការធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្មគ្រ័ចិត្ត និងរក្សាការសំងាត់ការផ្តល់សេវាអប់រំសុខភាពទូទៅ និងសុខភាពបន្តពូជ និងផែនការសុខភាពគ្រួសារ។

- ចំនួនបុរសស្រឡាញ់បុរសដែលបានមកពិគ្រោះយោបល់ និងផ្តល់ប្រឹក្សាក្នុងត្រីមាសទីមួយ:៤៦៦នាក់( ក្នុងគំរោង:៣៩០នាក់) មានអតិថជនចាស់៨៥នាក់ និងអតិថជនថ្មី៣៨១នាក់ ដែលក្នុងនោះអតិថជនចាស់ទទួលការព្យាបាលជំងឺកាមរោគ៣៤នាក់ និងអតិថជនថ្មីទទួលការព្យាបាលជំងឺកាមរោគ១៩១នាក់ និងអ្នកប្រើប្រាស់គ្រឿងញៀនDU/IDU ៩៨នាក់។

- ចំនួនស្រីស្រស់ដែលបានមកពិគ្រោះយោបល់ និងផ្តល់ប្រឹក្សាក្នុងត្រីមាសទីមួយ:

១៥៥នាក់(ក្នុងគំរោង:១៨០នាក់) មានអតិថជនចាស់៣០នាក់ និងអតិថជនថ្មី១២៥នាក់ ដែលក្នុងនោះអតិថជនចាស់ទទួលការព្យាបាលជំងឺកាមរោគ៤នាក់ និងអតិថជនថ្មីទទួលការព្យាបាលជំងឺកាមរោគ៣៩នាក់។

- មានបញ្ហាប្រឈមមួយចំនួន ទីតាំងគ្លីនិកនៅឆ្ងាយពីជនគោលដៅ
- សំភារៈមួយចំនួននៅមានការខ្វះខាត
- បរិក្ខារពេទ្យ និង ថ្នាំនូវមានការខ្វះខាត
- ថវិកានូវមានកំណត់
- អង្គការដៃគូមួយចំនួនមានទីតាំងនៅឆ្ងាយពីកន្លែងផ្តល់សេវា

២.៤ បទបង្ហាញពីបទពិសោធន៍ការផ្តល់សេវាសុភាពរបស់អង្គការកម្ពុជាបំបាត់ឈឺចាប់(PSC) ដែលមានកម្មវិធីៈ

- លើកកំពស់គុណភាពជីវិតនៃអ្នកឈឺចាប់ និងផ្តល់ជំនាញថែទាំសំរ៉ន់
- លើកកំពស់ការផ្តល់ និងការប្រើប្រាស់ថ្នាំបំបាត់ការឈឺចាប់(Opium)
- លើកកំពស់សកម្មភាពក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់
- អ្វីជាការថែទាំសំរ៉ន់? - ការថែទាំសំរ៉ន់ជាការថែទាំពិសេសមួយ និងផ្តល់ការគាំទ្រចំពោះជីវិតចុងក្រោយរបស់អ្នកជំងឺ ជាសំខាន់ការថែទាំសំរ៉ន់ទាក់ទងផងដល់ការថែទាំ និងគាំទ្រសំរាប់គ្រួសារ និងអ្នកជំងឺ។
- គោលបំណងនៃការថែទាំសំរ៉ន់ ជាការព្យាបាលរូបរាងកាយ អារម្មណ៍ សង្គម និងវប្បធម៌ និងស្មារតី។
-



៦.បញ្ហាប្រឈម:

• ក្រុមគោលដៅមួយចំនួនមានការចល័ត នៅលាក់មុខ និងមិនហ៊ានទទួលយកសេវាសុខភាពទូលំទូលាយនៅឡើយទេ។

• ក្រុមបុរសស្រឡាញ់បុរសមិនបានធ្វើតេស្តឈាម ដោយសារគាត់គិតថាការប្រព្រឹត្តរបស់គាត់មិនមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ទេ។

• ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ខ្លះពួកគាត់ជាប់រវល់ការងារ កំឡុងពេលអ្នកអប់រំតាមមូលដ្ឋានចុះធ្វើការអប់រំ និងធ្វើតេស្តឈាមនៅក្នុងសហគមន៍។

• មិនបានធ្វើតេស្តឈាមដោយគាត់ខ្លាចថាគាត់បានឆ្លងមេរោគអេដស៍ ។

• ខ្លាចការម៉ាក់ងាយ និងការរើសអើងពីគ្រួសារ និងសង្គម។

• អង្គការដៃគូមិនបានគោរពតាមគោលការណ៍ណែនាំរបស់ថ្នាក់ជាតិ។

• អ្នកអប់រំតាមមូលដ្ឋានមិនអាចធ្វើតេស្តជាពិសេសOWក្រោមគំរោងមូលនិធិសកល។

• គោលនយោបាយស្វែងរកបរិយាកាស គាំទ្រ មិនបានអនុវត្ត។

• អត្រាធ្វើតេស្តឈាមនៅមានកំរិតទាប ( ៥០% បដិសេធន៍មិនធ្វើតេស្ត )។

• មានការផ្លាស់ប្តូរ OW មានកំរិតខ្ពស់( ប្រហែល ៧០% ក្នុងមួយឆ្នាំ ។ )។

• ខ្វះខាត និងការផ្គត់ផ្គង់ប្រតិករសំរាប់ធ្វើតេស្តមិនទាន់ពេល។

• ខ្វះខាតឧបករណ៍សំរាប់អនុវត្តការធ្វើតេស្តឈាម។

• ពុំមានទូរទឹកកកសំរាប់រក្សាទុកដាក់ប្រតិករអោយគុណភាព។

• គុណភាណ និងកំរិតនៃការផ្តល់ប្រឹក្សា របស់OW នៅមានកំរិតទាប។

• ការស្វែងរកករណីថ្មីនៅមានកំរិតទាបជាពិសេសក្រុមលាក់មុខមិនអាចឆ្លើយតបតាមគោលការណ៍៩០ ៩០ ៩០ នាឆ្នាំ២០២០។

• ខ្វះខាតប្រតិករសំរាប់ធ្វើតេស្តឈាម ជាពិសេសតេស្តស្វាយ។

• ខ្វះឧបករណ៍សំរាប់អនុវត្តបំរើអោយការធ្វើតេស្តឈាម។

• ការអប់រំផ្សព្វផ្សាយដល់ក្រុម MSM&TG តាមបណ្តាខេត្តនានាមិនទាន់បានទូលំទូលាយ ទាំងការអប់រំឥរិយាបទ សីលធម៌សង្គម អតចរិក និងសេវាសុខភាព។

• ខ្វះការសិក្សាពីបរិបទរបស់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

• សមាជិក សមាជិការក្រុមលេខាធិការដ្ឋានចូលរួមកិច្ចប្រជុំប្រចាំខែមិនសូវបានទៀងទាត់ ។

• ការផ្តល់របាយការណ៍ ឬទិន្នន័យលើការងារបុរសស្រឡាញ់បុរស និងស្រីស្រស់នៅពេលស្នើសុំមានការយឺតយ៉ាវ។

• ម្ចាស់សេវាមួយចំនួនតូចមិនទាន់មានកិច្ចសម្របសម្រួលបានរលូននៅឡើយលើការចុះពិនិត្យ និងធ្វើតេស្តឈាមនៅតាមទីតាំង។

• មិនទាន់មានការគាំទ្រឬការផ្តល់អោយលើវិជ្ជាជីវៈសង្គមសម្រាប់ក្រុម MSM &TG ដើម្បីលើកកម្ពស់ជីវភាពរបស់ពួកគេ។

• មិនមានយន្តការច្បាស់លាស់ក្នុងការប្រមូលព័ត៌មានរបស់ក្រុមលេខាធិការដ្ឋាន។

• ភាពទន់ខ្សោយនៃបណ្តាញថ្នាក់ជាតិ។

• ក្រុមគោលដៅមួយចំនួននៅមានការរារែកក្នុងការទៅទទួលសេវាពិនិត្យសុខភាព។

• ចំណេះដឹងក្រុមគោលដៅនៅមានកំរិត។

**៧. សំណូមពរ និងអនុសាសន៍:**

• ត្រូវបង្កើតយន្តការច្បាស់លាស់ក្នុងការប្រមូលព័ត៌មានរបស់ក្រុមលេខាធិការដ្ឋានពីអង្គការដៃគូ ដោយកំណត់រៀងរាល់មួយត្រីមាសម្តង។

• ការរៀបចំផែនការសកម្មភាពរបស់ក្រុមការងារត្រូវកំណត់សុចន្ទករឲ្យបានច្បាស់លាស់។

• ការចុះអភិបាលកិច្ច ត្រូវមានផែនការ និងកំណត់គោលដៅច្បាស់លាស់ និងមានយុទ្ធវិធីក្នុងការចុះតាមដាន និងប្រមូលមកវិញនូវចំណុចខ្វះខាតនៅសហគមន៍ និងរកដំណោះស្រាយ។

• ត្រូវធ្វើការសិក្សាពីបរិបទ អតចរិករបស់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ដើម្បីកាត់បន្ថយការរើសអើង និងម៉ាក់ងាយក្នុងសង្គម។

• ត្រូវរកយុទ្ធវីធីថ្មីៗក្នុងការជំរុញលើកទឹកចិត្តដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រើប្រាស់ឲ្យបានជាប់លាប់នៅស្រោមអនាម័យ។

• ត្រូវជួយបណ្តាញថ្នាក់ជាតិក្នុងការពង្រឹងស្ថាប័នរបស់ខ្លួន និងដើរតួនាទីជាអ្នកសម្របសម្រួលតាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ(សហគមន៍)។

• សំណូមពរដល់សមាជិក សូមបរិចាគពេលវេលា ដើម្បីចូលរួមប្រជុំទាំងក្រុមការងារលេខាធិការដ្ឋាន ក៏ដូចក្រុមការងារបច្ចេកទេសឲ្យទៀងទាត់ និងគ្រប់ៗគ្នា។

• សំណូមពរដល់អ្នកធ្វើបទបង្ហាញជាខេមរៈភាសារ និងត្រួតពិនិត្យលើអក្ខរាវិរុទ្ធឲ្យបានត្រឹមត្រូវ។

• សូមជួយផ្តល់របាយការណ៍ ឬទិន្នន័យលើការងារបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅពេលស្នើសុំពីលេខាធិការដ្ឋាន។

• ពង្រឹង និងបង្កើនសមត្ថភាពដល់បុគ្គលិក និងអ្នកអប់រំផ្ទាល់។

• ក្រុមការងារលេខាធិការដ្ឋានត្រូវរៀបចំចងក្រងជាសៀវភៅនូវរបាយការណ៍ប្រចាំឆ្នាំ។

• ព្យាយាមស្វែងរកក្រុមគោលដៅថ្មី និងតាមដានគ្រប់ករណីដែលបានរកឃើញ។

• ព្យាយាមផ្តល់ការប្រឹក្សាបន្ថែមអំពីបញ្ហាសុខភាព ឥរិយាបទ និងសីលធម៌សង្គមដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

• ត្រូវរៀបចំកិច្ចប្រជុំ អាជ្ញាធរមូលដ្ឋានរៀងរាល់ត្រីមាស។

## ៨. ផែនការបន្ទាប់:

• ត្រូវរៀបចំកិច្ចប្រជុំសម្របសម្រួលរៀបចំប្រជុំក្រុមលេខាធិការដ្ឋាន និងប្រជុំប្រចាំត្រីមាសនៃក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រយុទ្ធនឹងជំងឺអេដស៍។

• សម្របសម្រួលរៀបចំប្រជុំប្រចាំត្រីមាសក្រុមការងារថ្នាក់ក្រោមជាតិនៃក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ប្រយុទ្ធនឹងជំងឺអេដស៍។

• បន្តរិះរកយុទ្ធវិធីដើម្បីចូលទៅដល់ក្រុមដែលលាក់មុខ ក្រុមប្រឈមមុខខ្ពស់ ដែលមិនបានអប់រំ ដើម្បីឲ្យពួកគេទទួលបានព័ត៌មានអំពីសុខភាព និងតាមដានអ្នកដែលមានផ្ទុកមេរោគអេដស៍ដើម្បីទទួលបានសេវាPreART/ART។

• បន្តចុះអប់រំ និងជំរុញការប្រើស្រោមអនាម័យ និងទឹករំអិលដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅពេលពួកគេចុះអប់រំជាក្រុម ឬអប់រំនៅតាមផ្ទះ។

• បន្តពង្រឹងបទអន្តរាគមន៍បង្ការ និងជំរុញក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ទៅរកសេវាពិនិត្យសុខភាព។

• ចុះអភិបាលកិច្ចទៅលើគុណភាពនៃការផ្តល់សេវាសុខភាព និងបញ្ហាប្រឈមនានា។

• ប្រមូលរបាយការណ៍ពីអង្គការដៃគូដែលធ្វើការជាមួយក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

• កិច្ចសហការណ៍ល្អជាមួយ អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវា បុគ្គលិកអង្គការ និងអ្នកទទួលផលធ្វើអោយប្រព័ន្ធនៃការបញ្ជូនទទួលបានជោគជ័យ។

• បណ្តុះបណ្តាលដល់អ្នកអប់រំតាមមូលដ្ឋានឲ្យមានចំណេះដឹងក្នុងការផ្តល់ប្រឹក្សាជាកត្តាធ្វើអោយក្រុមគោលដៅមានទំនុកចិត្តក្នុងការទៅទទួលសេវា។

• ជំរុញការធ្វើតេស្តចុងម្រាមដៃនៅក្នុងតំបន់ hot spot ធ្វើអោយក្រុមគោលដៅមិនមានការបាត់បង់ក្នុងការទៅទទួលសេវា។

• បន្តកិច្ចសហការជាមួយអាជ្ញាធរដែនដី និងកងកំលាំងមានសមត្ថកិច្ច និងអង្គការនៅសហគមន៍ និងក្រុមគោលដៅជួយការងារសង្គម ក្នុងគោលបំណងកាត់បន្ថយការមាក់ងាយ និងរើសអើងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

ជាទីបញ្ចប់ឯកឧត្តមប្រធានបានអរគុណ និងបានកោតសរសើរចំពោះសមាជិកដែលបានចូលរួមប្រជុំនាពេលនេះ និងសូមឲ្យខិតខំបន្តសហការគ្នាល្អ និងជំរុញការងារក្នុងការឆ្លើយតបការទប់ស្កាត់រីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ ដើម្បីសំរេចបាននូវគោលការណ៍៩០៩០៩០ នាឆ្នាំ២០២០ និង៩៥ ៩៥ ៩៥ នាឆ្នាំ២០២៥។

ភ្នំពេញថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៥

អ្នកធ្វើរបាយការណ៍

បានឃើញ និងពិនិត្យត្រឹមត្រូវ

បានឃើញ និងឯកភាព

ឯកឧត្តមអគ្គលេខាធិការ

ប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ